REVIEWED November 2004
NSWMulticulturalHealthCommunicationService

KHMER / ខ្មែរ
November 2000
[BHC-5695]

# ការដឹងពីគ្រោះថ្នាក់នៃការប្រើគ្រឿងញៀនម៉្យាងហៅ "អេចថេស៊្វី"

# Ecstasy - understanding the risks

"អេចថេស៊្វី" គឺជាគ្រឿងញៀនខុសច្បាប់ម៉្យាង ដែលជនវ័យក្មេងខ្លះប្រើ។ ក៏ប៉ុន្តែវាមិនដូចគ្រឿងញៀនឯទៀតដូចជាកញ្ឆា, អាភៀន(heroin) នឹងគ្រឿងញៀនម៉្យាងហៅ"ខូខេន"(cocaine)នោះទេ គ្រឿងញៀន "អេចថេស៊្វី"នេះមិនមានផ្សំមកពីជាតិរុក្ខជាតិឡើយ។ "អេចថេស៊្វី"គឺផលិតឡើងពីជាតិគីមីជាច្រើនមុខ។

## <u>តើ"អេចថេស៊្វី"ជាអ្វី</u> ?

ទោះបីជាតិផ្សំផលិត"អេចថេស៊្វី"អាចផ្លាស់ប្តូរខ្លះក្តី តែជាទូទៅ វាធ្វើមកពីជាតិគីមី ស្រដៀងទៅនឹងគ្រឿងញៀន២បែបផ្សេងទៀត ៖

- "អាំមហ្វីថាមីន" (amphetamines) ដែលជួនកាលគេហៅថា " ស្ពីដ" (speed) – គឺជាគ្រឿងលើកកម្លាំងម៉្យាង ហើយនិងជួយសំរាប់កុំឲ្យងងុយគេង។
- គ្រឿងញៀនម៉្យាងហៅ "ហាលឡូស៊ីនូហ្សេន"(Hallucinogens) នេះអាចធ្វើឲ្យអ្នកមើលឃើញ ឬឮអ្វីដែលគ្មានប្រភពសោះ ឬជួនកាលឮឬមើលឃើញអ្វីខុសផ្សេងពីរូបដើមទៅវិញ។ ឧទាហរណ៍ មនុស្សដែលញ៉ាំគ្រឿងញៀន"ហាលឡូស៊ីនូហ្សេន"(Hallucinogens) អាចមើលឃើញពែងកាហ្វេកំរើកដើរ ឬផ្ការនៅលើជញ្ជាំងចេះកំរើកដើរ។

## <u>តើគេប្រើគ្រឿងញៀន"អេចថេស៊្វី" (**Ecstasy**) តាមរបៀបណា</u> ?

តាមធម្មតាគេលេបគ្រឿងញៀន"អេចថេស៊្វី"នេះ ព្រោះវាមកជាគ្រាប់រាងមូលឬរាងផ្សេងៗពណ៌ស ឬលឿង ។ តែអ្នកខ្លះប្រើគ្រឿងញៀន"អេចថេស៊្វី"នេះតាមការចាក់។

## <u>តើវាមានឥទ្ធិពលអ្វីខ្លះ</u> ?

ឥទ្ធិពលនៃ"អេចថេស៊្វី" គឺយោងទៅតាមជាតិដែលគេដាក់ដាក់ផ្សំធ្វើគ្រឿងញៀននេះ ហើយនឹង យោងទៅតាមសាម៉ីខ្លួនដែលគ្រឿងញៀននោះ ។ វាអាចធ្វើឲ្យបុគ្គលនោះសប្បាយ មានការទុកចិត្តខ្លួនឯង និងបញ្ចេញសេចក្តីស្រឡាញ់។ ក៏ប៉ុន្តែវាក៏អាចធ្វើឲ្យបុគ្គលនោះមានអារម្មណ៍រសាប់រសល់ មានការភ័យខ្លាចថាមានអ្នកណាមកធ្វើបាប ហើយនិងមានដំណើរការធ្លាក់ទឹកចិត្តខ្លាំង។

ឥទ្ធិពលក្នុងកំឡុងពេលខ្លីមានដូចជា ៖

- ធ្វើឲ្យបេះដូងដើរញាប់ និងឡើងសម្ពាធឈាម
- សីតុណ្ហ:ភាព(កំដៅ)ក្នុងខ្លួនឡើង និងបែកញើស
- ការសោះទឹកពីក្នុងខ្លួន(dehydration)
- សង្កៀតធ្មេញ ឬខាំថ្គាម
- ចង់ក្អួត។

## តើ“អេចថេស្សី”ធ្វើឲ្យមានគ្រោះថ្នាក់ដូចម្តេចខ្លះ ?

អ្នកខ្លះស្លាប់ដោយសារប្រតិកម្មអាក្រក់ខ្លាំងនៃ“អេចថេស្សី”។ ទោះបីវាមិនសូវមានគ្រោះថ្នាក់ដល់ស្លាប់ក្តី តែយើងមិនដឹងជាមុនថាគ្រោះថ្នាក់ពីគ្រឿងញៀននេះនឹងកើតមានឡើងដល់បុគ្គលណា។ គ្រោះថ្នាក់ស្លាប់ខ្លះបណ្តាលមកពី ៖

- កំដៅខ្លាំងពេក – ដោយសារ“អេចថេស្សី” ព្រមជាមួយនិងការរាំរែកយូរពេក អាចធ្វើឲ្យសីតុណ្ហ:ភាពក្នុងខ្លួនឡើងក្តៅ បណ្តាលឲ្យសោះទឹកក្នុងខ្លួន។ អ្នកដែលប្រើគ្រឿងញៀន“អេចថេស្សី” គួរញ៉ាំទឹក ៥០០មីល្លីលីត្រក្នុង១ម៉ោងម្តងនៅពេលរាំរែកឬធ្វើសកម្មភាពផ្សេងៗ ហើយបើគ្មានការរាំរែកទេក៏គួរញ៉ាំទឹក២៥០មីល្លីលីត្រដែរ។
- ការញ៉ាំទឹកច្រើនពេក – វាជាការសំខាន់ដែលមិនត្រូវញ៉ាំទឹកច្រើនពេកក្នុង១លើក ព្រោះគ្រោះថ្នាក់ស្លាប់ខ្លះកើតឡើងកាលណាមានទឹកច្រើនដែលមានឥទ្ធិពលអាក្រក់ដល់ខួរក្បាល បណ្តាលឲ្យបាត់បង់ស្មារតីយូរ(coma)។

វាជាការសំខាន់ដែលអ្នកមិនត្រូវបើកបរជាដាច់ខាតនៅក្រោយពេលប្រើ“អេចថេស្សី” ហើយមិនត្រូវប្រើ“អេចថេស្សី”ជាមួយគ្រឿងញៀនផ្សេងទៀត ព្រមទាំងមិនត្រូវប្រើម្ហូលចាក់រួមគ្នាប្រសិនបើប្រើម្ជុលចាក់។ ជនណាដែលខ្លួនឯងឬគ្រួសារមានប្រវត្តិជម្ងឺខួរក្បាល ការព្រួយចិត្ត ការភ័យរន្ធត់ភ្លាមៗ(panic attacks) ជម្ងឺបេះដូង ការឡើងសម្ពាធឈាម ជម្ងឺទឹកនោមផ្អែម បញ្ហាថ្លើម ឬជម្ងឺឆ្កួតជ្រូក មិនត្រូវប្រើគ្រឿងញៀន“អេចថេស្សី”នេះទេ។

## តើ“អេចថេស្សី”ញៀនឬទេ ?

គេគ្មានជំនឿថា“អេចថេស្សី”បណ្តាលឲ្យញៀននោះទេ ឧទាហរណ៍វាមិនធ្វើឲ្យញៀនដូចអាភៀន ឬជាតិនីកូទីនក្នុងបារី ដែលវាធ្វើទុក្ខនៅពេលផ្តាច់ឈប់ប្រើ។ តែយ៉ាងណាក្តី ចំពោះជនខ្លះវាបណ្តាលឲ្យមានអារម្មណ៍ពឹងផ្អែកទៅលើ“អេចថេស្សី” – មានន័យថាជននោះពីបាកនិងឈប់ប្រើ“អេចថេស្សី” ពីព្រោះជននោះគឹតថា ខ្លួនត្រូវការ“អេចថេស្សី”ទើបមានអារម្មណ៍ល្អឬសប្បាយកើត។

## តើឥទ្ធិពលនៃការប្រើ“អេចថេស្សី”យូរពេលមានអ្វីខ្លះ ?

ភស្តុតាងខ្លះបានបង្ហាញឲ្យដឹងថា“អេចថេស្សី”មានឥទ្ធពលដល់ខួរក្បាល បណ្តាលឲ្យមានការព្រួយបារម្មណ៍និងដំណើរការធ្លាក់ទឹកចិត្តខ្លាំង។ ហេតុដូច្នេះហើយបានជាមានមនុស្សតិចណាស់ដែលប្រើ“អេចថេស្សី”យូរពេល ប្រហែលមកពីឥទ្ធិពលរបស់“អេចថេស្សី”ដែលធ្វើឲ្យសប្បាយនោះវាកាន់តែសាបទៅកាលណាប្រើយូរពេល។

## តើអ្នកអាចដឹងថាបុគ្គលណាប្រើ“អេចថេស្សី”ដែរឬទេ ?

ពីព្រោះឥទ្ធិពលនៃ“អេចថេស្សី”(និងគ្រឿងញៀនផ្សេងទៀត) មានសភាពប្រហាក់ប្រហែលទៅនិងអាកប្បកិរិយាក្មេងជំទង់ (ឧទាហរណ៍ ការផ្លាស់ប្តូរអារម្មណ៍ ការគេងយូរ) វាជាការពីបាកនិងឲ្យដឹងថាវាប្រើ“អេចថេស្សី”។ មាតាបិតាណាដែលមានការព្រួយបារម្មណ៍ពីកូនប្រើគ្រឿងញៀន ត្រូវទាក់ទងទៅវេជ្ជបណ្ឌិតឬមណ្ឌលសុខភាពសហគមន៍ (Community health centre) ដើម្បីយកពត៌មានស្តីពីផ្នែកបំរើខាងបញ្ហាគ្រឿងញៀននិងសុរាក្នុងតំបន់របស់អ្នក។



លេខទូរស័ព្ទទាំងនេះត្រឹមត្រូវនៅពេលបោះពុម្ពក៏ប៉ុន្តែអាចមិនបានកែតម្រូវតាមការលះទេស:។ លោក-ស្រី ប្រហែ អាចត្រូវមើលបញ្ជាក់លេខនៅក្នុង“សៀវភៅទូរស័ព្ទ” (Telephone Directory)។

## តើត្រូវធ្វើដូចម្តេចដែរប្រសិនបើមានអ្នកណាឈឺដោយសារការប្រើ“អេចថេស៊្វី” ឬគ្រឿង ញៀនផ្សេងទៀត ?

ប្រសិនបើសង្ស័យថាការឈឺនោះបណ្តាលមកពីការប្រើ“អេចថេស៊្វី” អ្នកត្រូវហៅឡានពេទ្យជាបន្ទាន់ (ប៉ូលីសមិនមកទេនៅពេលដែលអ្នកហៅឡានពេទ្យ)។

ប្រសិនបើអ្នកមានការពិបាកក្នុងការទូរស័ព្ទជាភាសាអង់គ្លេស សុំអ្នកទាក់ទងទៅផ្នែកផ្តល់អ្នកបកប្រែ Translating and Interpreting Service (អក្សរកាត់ **TIS**) លេខ 131 450។

អ្នកអាចយកពត៌មានផ្នែកសុខភាពបន្ថែមទៀតជាភាសាខ្មែរ ពីកំព្យូទ័រតាមរយះ **Multicultural Communication website at <http://mhcs.health.nsw.gov.au>.**